# IV. មន្ត្រីឥទាន

## Job Description

### 1. ផ្សព្វផ្សាយនិងលក់សេវាកម្មរបស់សហគ្រិន

- កំណត់តំបន់សក្តានុពលក្នុងការផ្សព្វផ្សាយនិងលក់សេវាកម្មតាមគោលការណ៍កំណត់
- ផ្សព្វផ្សាយអោយបានត្រឹមត្រូវតាមគោលនយោបាយ(បរិមាណនិងគុណភាព)
- ត្រូវមានផែនការផ្សព្វផ្សាយចុះផ្សព្វផ្សាយក្នុងតំបន់អោយបានទៀងទាត់ និងមានប្រសិទ្ធភាព

### 2. បង្កើនការទំនាក់ទំនងល្អជាមួយអាជ្ញាធរមូលដ្ឋាន

- ត្រូវចំណាយពេលវេលាក្នុងការជួបទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានជាប្រចាំ( យ៉ាងតិចម្តងក្នុងមួយខែជាមួយមេភូមិ និងមេឃុំ)
- ត្រូវមានការចូលរួមការងារសង្គមដូចជា កម្មវិធីប្រជុំ បុណ្យ ការ ...ជាមួយអាជ្ញាធរ

### 3. គ្រប់គ្រងតំបន់ប្រតិបត្តិការ

- ត្រួតពិនិត្យ និងក្តាប់ពីទីតាំងភូមិសាស្ត្រ ប្រជាជន ទីផ្សារហិរញ្ញវត្ថុ និងគូរប្រកួតប្រជែង
- ត្រួតពិនិត្យអំពីស្ថានភាពបំណុលនៅក្នុងប្រតិបត្តិការដែលខ្លួនគ្រប់គ្រង

### 4. សិក្សាស្រាវជ្រាវពីគូរប្រកួតប្រជែងក្នុងតំបន់

- ត្រូវសិក្សាពីចំណុចខ្លាំង និងខ្សោយរបស់គូរប្រកួតប្រជែងក្នុងតំបន់
- ត្រូវសិក្សាពីបំរែបំរួលអត្រាការប្រាក់ លក្ខណៈផលិតផល លក្ខខណ្ឌផ្សេងៗរបស់គូរប្រកួតប្រជែងរៀងរាល់៣ខែម្តង

### 5. គ្រប់គ្រងឥណទាន និងសេវាសង្គ្រោះគ្រួសារ

#### 5.1.ការបញ្ចេញឥណទាន

- រៀបចំផែនការបញ្ចេញឥណទានប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និងឆ្នាំ

- ប្រឹក្សា និងផ្តល់យោបល់ជូនអតិថិជនគោលដៅ ក្នុងការប្រើប្រាស់ឥណទាន
- ត្រួតពីនិត្យលទ្ធផលការងារធៀបជាមួយផែនការបញ្ចេញ
- សិក្សា និងវាយតំលៃប្រាក់កំចីស្របតាមគោលការណ៍កំណត់
- បណ្តុះវិន័យឥណទានដល់អតិថិជនអោយយល់ច្បាស់ពីគោលការណ៍កំណត់
- រៀបចំឯកសារអោយបានត្រឹមត្រូវ ធានាថាមានភាពគ្រប់គ្រាន់ និងស្របច្បាប់
- ធ្វើបញ្ជីភូមិណាដែលមិនត្រូវបានបញ្ចេញឥណទាន
- បើកប្រាក់ជូនអតិថិជនដល់ផ្ទះ តាមគោលការណ៍កំណត់
- សំរេចអោយបាន១០០%នៃផែនការទំលាក់ទុននិងសេវាផ្សេងៗទៀត
- សាកសួរឡើងវិញពីតំរូវការឥណទានរបស់អតិថិជន(អតិថិជបង់ដាច់ )
- ដោះស្រាយបណ្តឹងតវ៉ារបស់អតិថិជនក្នុងករណីមាន

5.2. **ការប្រមូលឥណទាន**

- ប្រមូលឥណទានដែលត្រូវសងប្រចាំថ្ងៃអោយទាន់ពេលវេលា
- ពិនិត្យរបាយការណ៍ប្រមូលកំចីប្រចាំថ្ងៃ
- ជូនដំណឹងពីកាលបរិច្ឆេទសងប្រាក់របស់អតិថិជន
- ពិនិត្យរបាយការណ៍អតិថិជនដែលដល់កិច្ចសន្យាសងប្រាក់ឡើងវិញ
- ធ្វើការប្រមូលប្រាក់សងអោយបាន១០០% និងទាន់ពេល

5.3. **ការដោះស្រាយឥណទាន**

- តាមដានការប្រើប្រាស់ទុនអោយស្របតាមគោលនយោបាយកំណត់
- កំណត់បញ្ហា និងពិភាក្សារកដំណោះដើម្បីឈានរកការសងត្រលប់ទាន់ពេលវេលា

- ត្រួតពិនិត្យឈ្មោះអតិថិជនដែលយឺតយ៉ាវមិនបានសងតាមកិច្ចសន្យា
- ចុះជួប និងដោះស្រាយ អោយអតិថិជនសងប្រាក់មកវិញតាមកិច្ចសន្យាថ្មី
- ចុះដោះស្រាយបំណុលយឺតយ៉ាវ និងកំណត់កិច្ចសន្យាជាក់លាក់ជូនអតិថិជន
- ធ្វើបញ្ជីលេខទូរសព្ទ័អតិថិជនដែលខ្លួនគ្រប់គ្រង
- មានចំណាត់ការសមស្រប និងទាន់ពេលវេលាលើកម្ចីយឺតយ៉ាវ
- ជូនពត៌មានទៅប្រធានមន្ត្រីឥណទានក្នុងករណីបំណុលយឺតយ៉ាវធ្ងន់ធ្ងរ ដើម្បីចាត់វិធានដោះស្រាយតាមផ្លូវច្បាប់

5.4. **ការគ្រប់គ្រងផលបត្រកំចី**

- តាមដានរបាយការណ៍ចំនួនអតិថិជន និងទឹកប្រាក់សកម្មប្រចាំថ្ងៃ ប្រចាំខែ ប្រចាំឆ្នាំ
- ត្រួតពិនិត្យភូមិណាដែលមានទឹកប្រាក់សកម្មតិចពេក ត្រូវរៀបចំផែនការបញ្ចេញឡើងវិញ ដោយមានសហការពីប្រធានមន្ត្រីឥណទាន
- ត្រួតពិនិត្យភូមិណាដែលមានទឹកប្រាក់សកម្មខ្ពស់ និងចំនួនអតិថិជនច្រើនពេក ត្រូវមានការប្រុងប្រយត្ន័ខ្ពស់ រឺត្រូវផ្អាកការបញ្ចេញបើចាំបាច់
- បើសិនក្នុងតំបន់របស់ខ្លួនមិនអាចមានអតិថិជនច្រើនទេ ត្រូវស្នើទៅប្រធានសាខាដើម្បីសុំពង្រឹងការផ្សព្វផ្សាយបន្ថែម
- ត្រូវមានផែនការបង្កើន និងត្រូវបង្កើនចំនួនអតិថិជនអោយបានជាលំដាប់

5.5. **ការងារសេវាសង្គ្រោះគ្រួសារ**

- ប្រឹក្សា ផ្តល់យោបល់ជូនអតិថិជនដើម្បីអោយចូលជាសមាជិក
- គ្រប់គ្រងការលក់សេវាសង្គ្រោះគ្រួសារ
- តាមដាន និងផ្តល់ដំណោះស្រាយចំពោះអតិថិជនដែលចូលជាសមាជិកសេវាសង្គ្រោះគ្រួសារ
- ចុះផ្ទាល់ក្នុងករណីមានសមាជិកទទួលមរណភាព និងរាយការណ៍ជូនប្រធានសាខា

- ចូលរួមជាសាក្សីផ្តល់ប្រាក់សំណងក្នុងករណីសមាជិកទទួលមរណភាព ។

6. **ទំនាក់ទំនងនិងថែរក្សាអតិថិជន**

- ត្រូវមានការទំនាក់ទំនងល្អជាមួយអតិថិជនថ្មី និងចាស់
- ចុះទំនាក់ទំនងអតិថិជនដែលបង់ដាច់ខែមុន
- ផ្តល់សេវាកម្មរហ័សប្រកបដោយវិជ្ជាជីវៈ
- មិនត្រូវជជែកឈ្លោះ ជាមួយអតិថិជន
- មានអោយអតិថិជនស្គាល់ និងមានប្រជាប្រិយភាពក្នុងតំបន់របស់ខ្លួន

7. **ការងារផ្សេងៗទៀតដែលប្រធានសាខាដាក់ជូនក្នុងក្របខណ្ឌសហគ្រិន**

- អាចនិងមានការងារផ្សេងក្រៅពីការចែងខាងលើក្នុងករណីប្រធានសាខា ឬ សហគ្រិន មានភាពចាំបាច់ ក្នុងគោលបំណងអោយស្ថាប័នមានភាពរីកចំរើន។

## Requirement

- កម្រិតសិក្សា៖ ចាប់ពីសញ្ញាបត្រទុតិយភូមិឡើងទៅ
- បទពិសោធការងារ៖ មានបទពិសោធន៍យ៉ាងតិច ១ ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុជាការល្អ
- ជំនាញផ្សេងៗ៖ ជំនាញទំនាក់ទំនង និងទីផ្សារ...
- ភាសារបរទេស៖ អាចអាន និងនិយាយភាសាអង់គ្លេសកាន់តែប្រសើរ ។
- ចំណេះដឹងកំព្យូទ័រ៖ MS office កាន់តែប្រសើរ
- មានជំនាញទំនាក់ទំនង និងអន្តរបុគ្គលិកល្អ ការងារជាក្រុម ម្ចាស់ការ និងលទ្ធផលការងារជាចម្បង។
- លទ្ធភាពទទួលការងារកិច្ចការងារច្រើន និងសាំញ៉ាំ ដែលត្រូវអនុវត្តក្នុងពេលតែមួយ។
- លទ្ធភាពធ្វើការងារដោយមិនមានការបង្អាប់បញ្ជារ ។
- មានភាពស្មោះត្រង់ខ្ពស់ គណនេយ្យភាព ឆន្ទៈការងារ វិន័យការងារ សមត្ថភាព និងការងារជាក្រុម ។

- មានការផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក
- មានប័ណ្ណបើកបរ